# សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ

## Announcement for risk recognition

សេចក្តីប្រកាសទទួលស្គាល់ហានិភ័យនេះមិនបង្ហាញនូវហានិភ័យទាំងអស់ ដែលអាចកើតមានពីប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទ នោះទេ។ ការធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទអាចប្រឈមនឹងហានិភ័យខ្ពស់ និងមានភាពស្មុគស្មាញច្រើន ដូចនេះ អតិថិជនត្រូវពិចារណាលើប្រភេទឧបករណ៍និស្សន្ទ បទពិសោធន៍ និងប្រភពហិរញ្ញវត្ថុរបស់អតិថិជនផ្ទាល់ ដើម្បីប្រាកដថាអតិថិជនអាចធ្វើប្រតិបត្តិការជួញដូរឧបករណ៍និស្សន៍បាន។ ទោះបីជាអតិថិជនធ្លាប់មានបទពិសោធន៍ក្នុងការជួញដូរឧបករណ៍និស្សន្ទក៏ដោយ ក៏អតិថិជននៅតែត្រូវយល់ដឹងអំពីហានិភ័យចម្បងៗដូចខាងក្រោម៖

This risk declaration does not represent all the risks arising from the trading of derivatives. Trading forex trades can be extremely risky and complicated, so Clients need to consider the type of instrument, experience, and financial resources of their own to make sure that Clients can trade in instruments. Even though the Client has experience in trading forex trader, they still need to be aware of the following key risks:

### ១- ឥទ្ធិពលនៃឡេវើរ៉េច ( Effect of Leverage )

មុននឹងអាចជួញដូរឧបករណ៍និស្សន្ទបាន ឈ្មួញជើងសា ឧបករណ៍និស្សន្ទតម្រូវឲ្យអតិថិជនដាក់សាច់ប្រាក់តម្កល់ ដែលត្រូវបានហៅថា ម៉ាជីនដំបូង។ ម៉ាជីនដំបូងនេះមានទំហំតូចធៀបនឹងតម្លៃជាក់ស្តែងនៃឧបករណ៍និស្សន្ទ ប៉ុន្តែអនុញ្ញាតឲ្យអតិថិជនអាចធ្វើការជួញដូរបានលើសពីទំហំសាច់ប្រាក់ជាក់ស្តែងដែលខ្លួនមាន តាមរយៈអានុភាពនៃឡេវើរ៉េច។ ក្នុងអំឡុងពេលជួញដូរ បម្រែបម្រួលថ្លៃឧបករណ៍និស្សន្ទនឹងប៉ះពាល់ដល់សាច់ប្រាក់តម្កល់របស់អតិថិជន ដែលអាចបង្កើតប្រាក់ចំណេញ ឬបង្កការខាតបង់ដល់អតិថិជន។ អតិថិជនអាចប្រឈមនឹងការខាតបង់ទាំងស្រុងនូវម៉ាជីនដំបូង និងសាច់ប្រាក់បន្ថែមដែលបានតម្កល់ជាមួយក្រុមហ៊ុន ដើម្បីរក្សាស្ថានភាពជួញដូររបស់ខ្លួន។

ក្នុងករណីកម្រិតម៉ាជីនរបស់អតិថិជនទាបជាងម៉ាជីនរក្សា អតិថិជននឹងទទួលបានម៉ាជីនខលពីឈ្មួញជើងសាឧបករណ៍និស្សន្ទ ដែលតម្រូវដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនី ក្នុងរយៈពេលជាក់លាក់មួយ ដើម្បីឲ្យកម្រិតម៉ាជីនក្នុងគណនីរបស់អតិថិជនកើនឡើងដល់លក្ខខណ្ឌតម្រូវ។ ក្នុងករណីអតិថិជនមិនបានដាក់សាច់ប្រាក់បំពេញបន្ថែមទៅក្នុងគណនីតាមការកំណត់ អតិថិជនមិនអាចដាក់បញ្ជាទិញ-លក់ឧបករណ៍និស្សន្ទបន្ថែម ហើយរាល់ស្ថានភាពជួញដូរឧបករណ៍និស្សន្ទទាំងអស់ ឬមួយផ្នែករបស់អតិថិជនត្រូវបានបិទ ដែលអាចបង្កការខាតបង់ដល់អតិថិជន។

Before trading forex trading, a forex broker requires clients to deposit cash, which is called initial margin. The first margin was small against the actual cost of the instrument, but allowed its clients to trade beyond the actual amount of cash it had through leverage. During trading, changes in the price of the instrument will affect the client's cash flow, which may generate profit or cause loss to the client. Clients may be at risk of losing the entire initial margin and additional cash invested with the company to maintain their trading status.

In case the client's margin is lower than the client's margin, the client will receive a margin from the broker, a derivative instrument that requires additional cash to be deposited into the account within a specified period of time so that the margin in the client's account reaches the required limit. In the event that the client does not deposit additional funds into the account, the client may not place additional trading instruments and all trades, or part of the client's trades, are closed, which could result in loss to the client.

### ២. ហានិភ័យនៃបញ្ជាបញ្ឈប់ការខាត ( Risks of Stop-Loss Order )

នៅក្នុងកាលៈទេសៈខ្លះ ដូចជាបម្រែបម្រួលថ្លៃលឿន ឬការបិទទីផ្សារ បញ្ជាបញ្ឈប់ការខាតមិនមានប្រសិទ្ធភាពនោះទេ ពោលគឺ បញ្ជាបញ្ឈប់ការខាតមិនអាចការពារអតិថិជនពីការខាតបានគ្រប់ពេលនោះទេ។

ក្នុងករណីមានភាពមិនប្រក្រតីនៃប្រព័ន្ធអេឡិចត្រូនិច បញ្ជារបស់អតិថិជនមិនអាចត្រូវបានអនុវត្ត ដែលអាចធ្វើឲ្យអតិថិជនប្រឈមនឹងហានិភ័យនៃការខាតក្នុងការដាក់បញ្ជាជួញដូរឧបករណ៍និស្សន្ទ ទោះបីជាអតិថិជនបានកំម្រិតទំហំខាតជាក់លាក់រួយហើយក៏ដោយ។

In some situations, such as a quick price hike or market closure, the stop loss problem does not work.

In the event of an irregularity in the system, the customer's problem may not be implemented, which would put the customer at risk of losing the forex trading order, even if the customer has fixed a certain amount of loss.

### ៣. បម្រែបម្រួលទីផ្សារមូលដ្ឋាន ( Underlying Market Volatility )

ឧបករណ៍និស្សន្ទគឺជាឧបករណ៍ដែលអនុញ្ញាតឲ្យអតិថិជនជួញដូរលើបម្រែបម្រួលថ្លៃក្នុងទីផ្សារមូលដ្ឋាន ឬឧបករណ៍មូលដ្ឋាន។ ទោះបីជាថ្លៃឧបករណ៍និស្សន្ទត្រូវបានផ្តល់ដោយក្រុមហ៊ុនសមភាគីកណ្តាលក៏ដោយ ក៏ថ្លៃនោះកើតចេញពីទីផ្សារមូលដ្ឋាន ឬឧបករណ៍មូលដ្ឋាន។ ដូចនេះ អតិថិជនត្រូវយល់ថា បម្រែបម្រួលទីផ្សារមូលដ្ឋានអាចជះឥទ្ធិពលលើថ្លៃឧបករណ៍និស្សន្ទ និងប្រាក់ចំណេញរបស់អតិថិជន។

អតិថិជនគួរយល់ដឹងផងដែរអំពីតម្លាភាពនៃព្រឹត្តិការណ៍ដែលអាចបង្កើតប្រាក់ចំណេញ ឬបណ្តាលឲ្យខាតនៅក្នុងគណនីអតិថិជន។ តម្លាភាពនៃព្រឹត្តិការណ៍ដែលអាចកើតឡើងនៅពេលទីផ្សារមូលដ្ឋានបើក ឬបិទ។ អតិថិជនត្រូវមានពេលវេលាគ្រប់គ្រាន់ដើម្បីតាមដានការវិនិយោគរបស់ខ្លួនឲ្យបានទៀងទាត់។

An index instrument is a tool that allows a client to trade on a bullish exchange in a local market or a local instrument. Even if the index instrument is provided by a central counterparty, it comes from the local market or the underlying instrument. Therefore, consumers need to understand that changes in basic market conditions can influence consumer prices, indicators and profitability.

Clients should also be aware of the transparency of events that could generate profit or cause losses in client accounts. Transparency of events that can occur when the local market is open or closed. Clients need to have enough time to monitor their investments regularly.

### ៤. ការផ្អាក ឬការដាក់កំហិតនៃការជួញដូរ ( Suspension or Restriction of Trading )

លក្ខខណ្ឌអស្ថេរភាពនៃទីផ្សារ ឬការអនុវត្តនៃវិធាននៃទីផ្សារមួយចំនួន អាចបង្កើនហានិភ័យនៃការខាតដោយសារអាចមានការលំបាក ឬមិនអាចធ្វើប្រតិបត្តិការទូទាត់ឬការកាត់កងស្ថានភាពជួញដូរបាន។

Market volatility or the enforcement of certain market rules may increase the risk of loss as a result of difficulties or inability to execute clearing or settlement positions

### ៥. សាច់ប្រាក់តម្កល់ ( Deposited Cash )

អតិថិជនត្រូវប្រាកដថា សាច់ប្រាក់ដែលខ្លួនបានដាក់តម្កល់សម្រាប់ប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទ ត្រូវបានរក្សាទុកនៅក្នុងគណនីសាច់ប្រាក់អតិថិជនឧបករណ៍និស្សន្ទនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។ អតិថិជនត្រូវយល់ដឹងថា ការដាក់តម្កល់សាច់ប្រាក់សម្រាប់ប្រតិបត្តិការជួញដូរឧបករណ៍និស្សន្ទនៅកន្លែងផ្សេង ជាអំពើផ្ទុយពីបទប្បញ្ញត្តិនិងប្រឈមនូវហានិភ័យខ្ពស់។

Clients must make sure that the cash they have deposited for trading the index instrument through a securities brokerage instrument is kept in the client's cash account, an index instrument, at a cash settlement agency that is recognized by the SECC. Consumers need to understand that depositing cash for trading securities elsewhere is against the law and is risky.

### ៦. កម្រៃជើងសា ថ្លៃសេវា និងចំណាយផ្សេងៗ ( Commission, Fee and other Charges )

មុនធ្វើការជួញដូរ អតិថិជនត្រូវទទួលបានការពន្យល់ច្បាស់លាស់អំពីកម្រៃជើងសា ថ្លៃសេវា ការប្រាក់ឆ្លងថ្ងៃ (Swap) និងចំណាយផ្សេងៗ ដែលអតិថិជនត្រូវទទួលបន្ទុក។ ចំណាយទាំងនេះនឹងប៉ះពាល់ដល់ប្រាក់ចំណេញសុទ្ធ ឬកំណើននៃការខាតរបស់អតិថិជន។

Prior to doing business, the customer must provide a clear explanation of the commissions, fees, fees and other charges incurred by the customer. These costs will affect net profit or growth of customer loss.

### ៧. ហានិភ័យរូបិយប័ណ្ណ ( Currency Risks )

ប្រតិបត្តិការជួញដូររូបិយប័ណ្ណបរទេសនឹងប៉ះពាល់ដល់ការចំណេញ ឬខាតរបស់អតិថិជន ដោយសារបម្រែបម្រួលនៃអត្រាប្តូរប្រាក់ ដែលតម្រូវឲ្យប្តូរពីរូបិយប័ណ្ណបរទេសនោះជារូបិយប័ណ្ណផ្សេងទៀត។

Foreign exchange transactions will affect customer profit or loss as a result of changes in the exchange rate required to convert foreign currencies to other currencies.

### ៨. ហានិភ័យសន្ទនីយភាព ( Liquidity Risks )

ឧបករណ៍និស្សន្ទខ្លះអាចមានកម្រិតសន្ទនីយភាពទាប ឬមិនមានសន្ទនីយភាព ដោយសារការចុះនៃតម្រូវការ ដែលធ្វើឲ្យអតិថិជនមិនអាចលក់ឧបករណ៍និស្សន្ទនោះ ឬមិនអាចទទួលបានព័ត៌មានអំពីថ្លៃឧបករណ៍និស្សន្ទនោះ ឬហានិភ័យពាក់ព័ន្ធ ដោយងាយស្រួល។

Some index instruments may have low or no fluidity due to a drop in demand that prevents the consumer from selling the instrument or is unable to easily obtain information about the instrument price or associated risk.

### ៩. ហានិភ័យនៃការអនុវត្តបញ្ជា ( Execution Riske )

ហានិភ័យនេះអាចកើតឡើងក្នុងករណីដែលបញ្ជាទិញ-លក់ឧបករណ៍និស្សន្ទមិនត្រូវបានអនិវត្តភ្លាមៗ។

**ឧទាហរណ៍៖** អាចមានការពន្យាពេលរវាងពេលដែលអតិថិជនដាក់បញ្ជា និងពេលដែលបញ្ជាត្រូវបានអនុវត្ត។ ដូចនេះ បញ្ជាងាចមិនត្រូវបានអនិវត្តនៅក្នុងថ្លៃដែលអតិថិជនរំពឹងទុក។

ហានិភ័យនេះក៏អាចកើតមានក្នុងករណីជួញដូរក្រោយទីផ្សារបិទផងដែរ។ អតិថិជនត្រូវដឹងថា ថ្លៃសម្រាប់ការជួញដូរអាចមានភាពខុសគ្នាពីថ្លៃបិទនៃឧបករណ៍មូលដ្ឋាន ពោលគឺ គម្លាតថ្លៃនៅពេលទីផ្សារបិទអាចមានទំហំធំជាងគម្លាតថ្លៃនៅពេលទីផ្សារបើក។

This risk can occur if the order for the instrument is not immediate.

**Example,** there may be a delay between when the customer places the order and when the order is executed. Therefore, the order cannot be carried out at the price the customer expects.

This risk can also occur in the case of after-market trading. Customers need to be aware that trading prices can be different from the closing price of a basic device, that is, the price gap at the closing market can be larger than the price gap when the market is open.

### ១០.ហានិភ័យសមភាគី ( Counterpart Risks )

អតិថិជនត្រូវដឹងថា ការជួញដូរឧបករណ៍និស្សន្ទតាមរយៈឈ្មួញជើងសាឧបករណ៍និស្សន្ទ គឺជាការជួញដូររវាងអតិថិជន និងក្រុមហ៊ុនសមភាគីកណ្តាលដែលជាភាគីម្ខាងទៀតនៃកិច្ចសន្យា ដែលឈ្មួញជើងសាឧបករណ៍និស្សន្ទជាភ្នាក់ងារ។ ការណ៍នេះបញ្ជាក់ថា ក្រុមហ៊ុនសមភាគីកណ្តាលគឺជាសមភាគីរបស់អតិថិជននៅប្រត្តបត្តិការជួញដូរឧបករណ៍និស្សន្ទ។ ដូចនេះ មុនពេលធ្វើប្រត្តបត្តិការជួញដូរ អតិថិជនត្រូវស្វែងយល់អំពីអាជ្ញាបណ្ណវិធានប្រត្តបត្តិការឧបករណ៍និស្សន្ទ និងព័ត៌មានសំខាន់ផ្សេងទៀតរបស់ក្រុមហ៊ុនសមភាគីកណ្តាល ដែលឈ្មួញជើងសាឧបករណ៍និស្សន្ទបានតភ្ជាប់ប្រព័ន្ធជួញដូរឧបករណ៍និស្សន្ទជាមួយ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលអាចសម្រួលដល់អតិថិជនក្នុងការធ្វើប្រត្តបត្តិការជួញដូរ និងកាត់បន្ថយនូវហានិភ័យដែលអាចកើតមាន។

Customers need to know that trading of the forex trader is a trading instrument between the client and his / her counterpart counterpart which is on the other side of the contract to which the forex broker is an agent. This implies that the central counterparty is the client's counterpart in the trading instruments. Therefore, before conducting a trading transaction, the client must know about the license, the operating instrument, the index and other important information of the central counterparty, where the forex broker has connected the forex trading system with relevant provisions that may facilitate the client to do so. Trading operations and reducing the potential risk.

**១១. ការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិច** ( Electronic Trading )

សម្រាប់ការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិច អតិថិជនអាចប្រឈមនឹងហានិភ័យទាក់ទងនឹងប្រព័ន្ធជួញដូរដែលអាចមានការខូចផ្នែករឹង (Hardware) និង/ ឬផ្នែកទន់ (Software)។ ការខូចផ្នែកណាមួយនៃជួញដូរបញ្ជាទិញ-លក់របស់អតិថិជនអាចមិនត្រូវបានអនុវត្តតាមការដាក់បញ្ជា ឬមិនត្រូវបានអនុវត្តទាំងស្រុង។ ក្នុងករណីនេះ អតិថិជនត្រូវបញ្ជាក់ជាមួយក្រុមហ៊ុនដើម្បីធ្វើការដោះស្រាយ។

For e-commerce, customers may be exposed to risks associated with trading systems that may have hardware problems and / or software failures. Damage to any portion of a customer's order may not be complied with or may not be fully complied with. In this case, the customer must confirm with the company for settlement.

ខ្ញុំសូមប្រកាសទទួលស្គាល់ថា បានទទួលការពន្យល់ពីភ្នាក់ងារជើងសាឧបករណ៍និស្សន្ទ និងយល់ដឹងអំពីហានិភ័យពាក់ព័ន្ធនឹងការជួញដូរឧបករណ៍និស្សន្ទ។

I would like to acknowledge that I have received explanations from the forex brokers and are aware of the risks associated with trading instruments.

| **សម្រាប់អតិថិជនជារូបវន្តបុគ្គល** | **សម្រាប់អតិថិជនជានីតិបុគ្គល** |
|---|---|
| ហត្ថលេខា ឈ្មោះពេញ របស់អតិថិជន<br>Signature, full name of client.<br><br><br>កាលបរិច្ឆេទ Date............................................ | ហត្ថលេខា ឈ្មោះពេញរបស់អ្នកតំណាងក្រុមហ៊ុន និងត្រារបស់ក្រុមហ៊ុន<br>Signature or finger print, full name and stamp of company<br><br><br>កាលបរិច្ឆេទ Date................................................. |

Unit V8D,8th Floor, Trust Tower Czechoslovakia Boulevard, Street 169, Phnom Penh 12253, Cambodia
Phone: (855) 23 883 122